# សេចក្តីប្រកាសពីការការពារ របស់ព្រះជាម្ចាស់

**ឯគ្រឿងសស្ត្រាវុធ**ណាដែលគេធ្វើឡើង នោះគ្មានអ្វីមួយអាចទាស់នឹងខ្ញុំបានឡើយ ហើយអស់ទាំងអណ្តាតណាដែលកំរើកទាស់នឹងខ្ញុំក្នុងរឿងក្តី នោះទ្រង់នឹងកាត់ទោសឲ្យវិញ នេះហើយជាមរដក ដែលខ្ញុំបានទទួលពីព្រះយេហូវ៉ា ដូចជាពួកអ្នកដែលបំរើដល់ព្រះអម្ចាស់ ហើយសេចក្តីសុចរិតរបស់ខ្ញុំក៏មកពីទ្រង់ដែរ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា។១ ប្រសិនបើមានអ្នកណាម្នាក់បានមកនិយាយបង្ខូច មកទាស់ប្រឆាំង ឬក៏ មកធ្វើបាប ព្រមទាំងបដិសេធនឹងខ្ញុំ នោះខ្ញុំនឹងអត់ទោសឱ្យ ហើយខ្ញុំនឹងអោយពរដល់ពួកគេ នៅក្នុងព្រះនាមព្រះអម្ចាស់វិញ។២

**ឥឡូវនេះ** បពិត្រព្រះអម្ចាស់អើយ ទូលបង្គំសូមប្រកាសថា ទ្រង់នេះហើយ គឺជាព្រះអម្ចាស់នៃទូលបង្គំតែមួយគត់ ហើយគ្មានព្រះផ្សេងទៀតក្រៅពីទ្រង់ទេ ទ្រង់គឺជាព្រះអង្គសង្គ្រោះ ជាព្រះវរបិតា ជាព្រះរាជបុត្រា ហើយជាព្រះវិញ្ញាណបរិសុទ្ធ ដែលសាកសមឱ្យទូលបង្គំថ្វាយបង្គំ!

**ទូលបង្គំ**សូមប្រគល់ខ្លួនរបស់ទូលបង្គំ ដើម្បីចុះចូលក្នុងការស្តាប់បង្គាប់ទ្រង់ដោយគ្មានដែនកំនត់។ទូលបង្គំនឹងចុះចូលជាមួយទ្រង់ ឱព្រះអម្ចាស់អើយ ទូលបង្គំនឹងធ្វើ នូវអ្វីដូចដែលព្រះបន្ទូលរបស់ទ្រង់ បានបង្គាប់មកទូលបង្គំ។ទូលបង្គំនឹងប្រឆាំងនឹងវិញ្ញាណអាក្រក់ ដូចជា៖ គ្រប់ទាំងការគាបសង្កត់ ការវាយប្រហារ ការបោកប្រាស់ ព្រមទាំងពួកពលបរិវារ ឬក៏តាមវិធីផ្សេងៗរបស់វា ដែលវាប្រើមកប្រឆាំងនឹងទូលបង្គំ ទូលបង្គំនឹងមិនចុះចូលជាមួយវាទេ! គឺប្រឆាំងនឹងវាវិញ ហើយនឹងបណ្តេញវា ព្រមទាំងដកវាចេញពីទូលបង្គំ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ជាពិសេសទូលបង្គំនឹងប្រឆាំង ហើយនិងដកចេញនូវ៖ ភាពទន់ខ្សោយ ការឈឺចាប់ ការឆ្លងមេរោគ ការរលាក ជម្ងឺមហារីក អាឡែស៊ី មេរោគ និងគ្រប់ទាំងទម្រង់ នៃអំពើអាបធ្មប់ ព្រមទាំងភាពតានតឹង។

**ជាចុងក្រោយ** ឱព្រះអម្ចាស់អើយ ទូលបង្គំសូមអរព្រះគុណដល់ទ្រង់តាមរយៈការពលីព្រះជន្មរបស់ព្រះយេស៊ូវ នៅលើឈើឆ្កាង នោះជាហេតុដែលធ្វើឱ្យទូលបង្គំបានឆ្លងផុតពីការស្ថិតក្រោមបណ្តាសា ហើយបានចូលទៅក្នុងព្រះពររបស់លោកអ័ប្រាហាំ ដែលទ្រង់ផ្តល់ព្រះពរក្នុងគ្រប់កិច្ចការទាំងអស់ ៣ ៖ ការលើកតម្កើង សុខភាពល្អ ការបង្កើតកូនចៅ ទ្រព្យសម្បត្តិ ការទទួលជ័យជម្នះ និងជាទីគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់។

**អេសាយ ៥៤: ១៧** ឯគ្រឿងសស្ត្រាវុធណាដែលគេធ្វើឡើង នោះគ្មានណាមួយនឹងអាចទាស់នឹងឯងបានឡើយ ហើយអស់ទាំងអណ្តាតណាដែលកំរើកទាស់នឹងឯងក្នុងរឿងក្តី នោះឯងនឹងកាត់ទោសឲ្យវិញ នេះហើយជាសេចក្តី ដែលពួកអ្នកបំរើរបស់ព្រះយេហូវ៉ា នឹងទទួលជាមរដក ហើយសេចក្តីសុចរិតរបស់គេក៏មកពីអញ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា។

**ម៉ាថាយ ៥: ៤៣-៤៥** អ្នករាល់គ្នាបានឮសេចក្តី ដែលថ្លែងទុកមកថា «ចូរស្រឡាញ់អ្នកជិតខាងឯង តែស្អប់ខ្មាំងសត្រូវឯងវិញ» ៤៤ ប៉ុន្តែខ្ញុំប្រាប់ថា ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ ត្រូវឲ្យពរដល់អ្នកណាដែលប្រទេចផ្តាសា ត្រូវប្រព្រឹត្តល្អនឹងអ្នកណាដែលស្អប់អ្នករាល់គ្នា ហើយត្រូវអធិស្ឋាន ឲ្យអ្នកណាដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នាវិញ ៤៥ ដើម្បីឲ្យបានធ្វើជាកូនរបស់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ព្រោះទ្រង់ធ្វើឲ្យថ្ងៃរបស់ទ្រង់រះឡើង បំភ្លឺទាំងមនុស្សអាក្រក់ និងមនុស្សល្អ ហើយទ្រង់បង្អុរឲ្យភ្លៀងធ្លាក់មក លើទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតផង។

**រ៉ូម ១២: ១៤** ចូរសូមពរឲ្យដល់អ្នកណាដែលបៀតបៀនអ្នក ចូរសូមពរចុះ កុំឲ្យប្រទេចផ្តាសាឡើយ ។

**កាឡាទី ៣: ១៣-១៤** ព្រះគ្រីស្ទទ្រង់បានលោះយើងរាល់គ្នា ឲ្យរួចពីសេចក្តីបណ្តាសារបស់ក្រឹត្យវិន័យ ដោយទ្រង់ត្រូវបណ្តាសាជំនួសយើងរាល់គ្នា (ដ្បិតមានសេចក្តីចែងទុកមកថា «ត្រូវបណ្តាសាហើយ អ្នកណាដែលត្រូវព្យួរនៅលើឈើ») ១៤ ដើម្បីឲ្យពររបស់លោកអ័ប្រាហាំ បានមកដល់អស់ទាំងសាសន៍ក្នុងព្រះគ្រីស្ទយេស៊ូវ ប្រយោជន៍ឲ្យយើងបានទទួលសេចក្តីសន្យា គឺជាព្រះវិញ្ញាណ ដោយសារសេចក្តីជំនឿ។

**លោកុប្បត្តិ ២៤:១** ឯអ័ប្រាហាំគាត់ចាស់ណាស់ហើយ មានអាយុវែង ហើយព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់គាត់ក្នុងគ្រប់ការទាំងអស់។

**បកប្រែដោយ: ONE- 2- ONE CAMBODIA**
**អាស័យដ្ឋាន: # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC01